CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 13 ខែឧសភា ឆ្នាំ 2021
ទំនាក់ទំនង ៖ លោក ជេន ហ្គ្រូប៊េធី (Jane Grobaty) មន្ត្រីព័ត៌មានសហគមន៍, 562.570.3233, Jane.Grobaty@longbeach.gov.

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# នាយកដ្ឋានឧទ្យាន ការកំសាន្ត និងសមុទ្រ ឡុងប៊ិច នឹងចាប់ផ្តើមដំណើរការ ឡើងវិញ ដើម្បីផ្តល់ការអនុញ្ញាត ឱ្យកក់ទីតាំងធ្វើភិកនិក និងដំបូលទីតាំងសម្រាក នៅថ្ងៃទី 24 ខែឧសភា ។

ឡុងប៊ិច, CA - នាយកដ្ឋានឧទ្យាន ការកំសាន្ត និងសមុទ្រ នៃសាលាក្រុងឡុងប៊ិច (PRM) នឹងចាប់ផ្តើមដំណើរការ ឡើងវិញ ដើម្បីផ្តល់ការអនុញ្ញាត ឱ្យកក់ទីតាំងធ្វើភិកនិក, ដំបូលទីតាំងសម្រាក និង សាលមហោស្រព បើកចំហរ នៅថ្ងៃទី 24 ខែឧសភា ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Mayor Robert Garcia) «ដោយសារកិច្ចខិតខំប្រឹងប្រែងរួម របស់យើង ក្នុងការកាត់បន្ថយការឆ្លងរាគត្បាត COVID-19 ជាសាកល, ទីក្រុងរបស់យើងបានឈានទៅកាន់ ស្រទាប់ពណ៌លឿង ដែលអាចអនុញ្ញាតឱ្យ ប្រជាពលរដ្ឋ អាចជួបជុំគ្នាបាន ក្នុងចំនួនតិចជាង 100 នាក់ នៅតាមទីវាល ដែលបានកក់រួច ក្នុងឧទ្យាន ។» «យើងខ្ញុំទន្ទឹងថា នឹងអាចចេញលិខិតអនុញ្ញាត សម្រាប់ព្រឹត្តិការណ៍ នៅក្នុងអគារ នៅមជ្ឈមណ្ឌលសហគមន៍ តាមឧទ្យាននានា នាពេលឆាប់ៗ ខាងមុខនេះ ។»

ទីតាំង នៅទីវាល ដែលអាចកក់បាន រួមមាន ទីកន្លែងធ្វើភិកនិក នៅឧទ្យាន អ៊ែល ដូរ៉ាដូ (El Dorado) ប៉ែកខាងលិច, ដំបូលទីតាំងសម្រាក នៅឧទ្យានប៊ិកប៊ី (Bixby) និងឧទ្យានកំសាន្ត, និងសាលមហោស្រព បើកចំហរ នៅឧទ្យាន ស៊ីហ្សា អ៊ី សាវេ (Cesar E. Chavez) និង ទីកន្លែងធ្វើភិកនិក នៅឧទ្យាន តំបន់ អ៊ែល ដូរ៉ាដូ (El Dorado) ។ ត្រូវស្នើសុំ លិខិតអនុញ្ញាត យ៉ាងហោចណាស់ ឱ្យបាន ពីរសប្តាហ៍ មុនពេលព្រឹត្តិការណ៍ដំណើរការ ។

សេចក្តីលំអិត ពាក់ព័ន្ធនឹង ពាក្យស្នើសុំលិខិតអនុញ្ញាត ថ្លៃសេវា និងព័ត៌មានផ្សេងៗ ទៀត សម្រាប់ទីតាំង PRM ទាំងអស់ អាចរកបាន តាមអ៊ីនធឺណែត ដោយចូលទៅ LBparks.org ហើយចុចលើ «លិខិតអនុញ្ញាតកក់សម្បទា (Facility Reservations Permits)» ។ អ្នកដែលមានចំណាប់អារម្មណ៍ ចង់ស្នើសុំលិខិតអនុញ្ញាត សម្រាប់ទីតាំងជាក់លាក់ណាមួយ គួរគោរពតាមសេចក្តីណែនាំ ដូចខាងក្រោមនេះ ៖

- **ទីកន្លែងធ្វើភិកនិក នៅឧទ្យាន អ៊ែល ដូរ៉ាដូ (El Dorado) ប៉ែកខាងលិច, ដំបូលទីតាំងសម្រាក នៅឧទ្យានប៊ិកប៊ី (Bixby) និងឧទ្យានកំសាន្ត, និងសាលមហោស្រព បើកចំហរ នៅឧទ្យាន ស៊ីហ្សា អ៊ី សាវេ (Cesar E. Chavez) ។**
    - សូមមកដោយផ្ទាល់ នៅការិយាល័យកក់ PRM ដែលមានអាសយដ្ឋានលេខ 2670 ផ្លូវ អ៊ែន ស្ទូដប៉ែកឃើ (N. Studebaker Road.) ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹក

ដល់ម៉ោង 5 ល្ងាច (ចាំបាច់ត្រូវធ្វើការណាត់ជួប ទុកជាមុន ដើម្បីមកកាន់ការិយាល័យ កក់ PRM ហើយការណាត់ជួបនេះ អាចធ្វើទៅបាន តាមអ៊ីនធឺណែត ។ វគ្គណាត់ជួបចុងក្រោយគេ គឺនៅម៉ោង 4 ល្ងាច ។)
    - ទម្រង់បែបបទ និងប័ណ្ណបើកបរ អាចផ្ញើតាម PRM-Info@longbeach.gov ឬ ផ្ញើតាមទូរសារលេខ 562.570.3113 បាន ។ តំណាងការិយាល័យ នឹងទាក់ទងទៅអតិថិជន ឱ្យបំពេញពាក្យសស្នើសុំ ហើយរៀបចំការទូទាត់ តាមអ៊ីនធឺណែត នៅថ្ងៃដដែល សម្រាប់អតិថិជន នៅពេលលិខិតអនុញ្ញាត ត្រូវបានបង្កើតឡើង និងមានការឯកភាពរួច ។ ប្រសិនបើមិនបានទូទាត់ នៅល្ងាចថ្ងៃដដែលនោះទេ លិខិតអនុញ្ញាតនឹងត្រូវលុបចោល ។ សម្រាប់ព័ត៌មានបន្ថែមទៀត គេអាចទូរសព្ទទៅលេខ 562.570.3111 ។
- **ទីកន្លែងធ្វើភិកនិក (Picnic) នៅឧទ្យាន តំបន់ អ៊ែល ដូរ៉ាដូ (El Dorado)**
    - សូមមកដោយផ្ទាល់ នៅមជ្ឈមណ្ឌលទទួលភ្ញៀវ នៃមជ្ឈមណ្ឌលធម្មជាតិ នៅឧទ្យាន អ៊ែល ដូរ៉ាដូ (El Dorado) ដែលមានអាសយដ្ឋានលេខ 7550 វិថី អ៊ី ស្ព្រីង (E. Spring St.) ពីថ្ងៃអង្គារ ដល់ថ្ងៃអាទិត្យ ចាប់ពីម៉ោង 8:30 ព្រឹក ដល់ម៉ោង 4 ល្ងាច ។
    - ពាក្យស្នើសុំ អាចយកមកដាក់ នៅពេលដដែលបាន ហើយនឹងត្រូវដំណើរការ នៅថ្ងៃធ្វើការបន្ទាប់ ។ បុគ្គលិក និងទាក់ទងទៅភ្ញៀវ ឱ្យបំពេញពាក្យស្នើសុំ ។ សម្រាប់ព័ត៌មានបន្ថែមទៀត សូមទូរសព្ទទៅលេខ 562.570.1750 ។

ព័ត៌មាន អំពីទីតាំងធ្វើភិកនិក ដែលអាចកក់បាន និងថ្លៃទីតាំង អាចរកបាន នៅ គេហទំព័រ សម្រាប់កក់សម្បទា PRM ។

ពាក្យស្នើសុំការអនុញ្ញាត និងទម្រង់បែបបទវិធាន មាននៅ គេហទំព័រ សម្រាប់កក់សម្បទា PRM ។

ដើម្បីគោរពតាម បទបញ្ជាសុខាភិបាលក្រុង បច្ចុប្បន្ននេះ នៅកម្រិត (អប្បបរមា) ពណ៌លឿង, ពិធិសារសុខាភិបាល ចំពោះ COVID-19 សម្រាប់ទីកន្លែងធ្វើភិកនិក និងការកក់ដំបូលទីតាំងសម្រាក (bandshell) រួមមាន៖

- រក្សាគម្លាតពីគ្នា ឱ្យបានយ៉ាងហោចណាស់ ប្រាំមួយហ្វីត ទោះបីជាមានពាក់របាំងមុខហើយក្តី ។
- សូមលាងសម្អាតដៃ ជាមួយសាប៊ូ និងទឹក ឱ្យបានយ៉ាងហោចណាស់ 20 វិនាទី ឬ ប្រើប្រាស់ទឹកកម្ចាត់មេរោគ ដែលមានជាតិអាល់កុល យ៉ាងហោចណាស់ 60% ឱ្យបានញឹកញាប់ តាមដែលអាចធ្វើទៅបាន ។
- សូមជៀសវាងការចាប់ដៃគ្នា ។
- សូមកុំចូលរួម ប្រសិនបើលោកអ្នកឈឺ ។
- សូមពាក់របាំងមុខ ។

ការកក់ PRM បានបញ្ចប់ កាលពីឆ្នាំមុន ដោយសារការដាក់កំហិត ផ្នែកសុខភាពសាធារណៈ និងការប្រុងប្រយ័ត្ន ដើម្បីសុវត្ថិភាព ពាក់ព័ន្ធនឹង ការឆ្លងរាតត្បាត COVID-19 ជាសាកល ។ សព្វថ្ងៃនេះ ឡុងប៊ិច បានឃើញ ការធ្លាក់ចុះ យ៉ាងគំហុក និងជាបន្តបន្ទាប់ ចំពោះករណីឆ្លង និងចូលទៅព្យាបាល នៅមន្ទីរពេទ្យ ពាក់ព័ន្ធនឹង COVID-19 ហើយនៅពេលដែលប្រជាពលរដ្ឋកាន់តែ មានភាពស៊ាំទៅ នោះ PRM នឹងអាចបើកឱ្យធ្វើការកក់ ជាថ្មីម្តងទៀតបាន។

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ long-beach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

# # #